ទីស្តីការ

ក្រសួងយុត្តិធម៌ និង ក្រសួងបរិស្ថាន

លេខ ៤០ ប្រក.កយ.បស្ថ-២០០២

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រកាសរួម

## ស្តីពី

## ការដាក់ឲ្យប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថាន ដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថាន

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ

-បានឃើញក្រឹត្យលេខ២១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ ស្តីពីវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ - មាត្រា ៩០ និង មាត្រា ៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញក្រឹត្យលេខ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី នៃរដ្ឋកម្ពុជា

-បានឃើញអនុក្រឹត្យលេខ១៩ អនក្រ-បក ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ-បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-បានឃើញអនុក្រឹត្យលេខ២៧ អនក្រ-បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

-បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ-បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង

-បានឃើញអនុក្រឹត្យលេខ៤២ អនក្រ-បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង

-តាមសំណើរបស់ក្រសួងបរិស្ថានលេខ ៦១២សណ/បស្ថ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២

**សម្រេច**

**ប្រការ ១** ត្រូវបានទទួលស្គាល់ដោយច្បាប់ជាមន្ត្រីនគរបាលយុត្តិធម៌ ឬ អាចបំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីក្រសួងបរិស្ថាន រួមមានៈ

-អគ្គនាយក អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

-ប្រធាន អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានការិយាល័យកិច្ចការច្បាប់ នៃនាយកដ្ឋានផែនការនិងកិច្ចការច្បាប់

-ប្រធាន អនុប្រធាន នាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ និងប្រធាន អនុប្រធាន

-ការិយាល័យឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ

-ការិយាល័យតំបន់ដីសើម ទីជម្រាល និងតំបន់ឆ្នេរ

-នាយក នាយករងស្នាក់ការតំបន់ការពារធម្មជាតិ នៃនាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ

-ប្រធាន អនុប្រធាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន និងប្រធាន អនុប្រធាន

-ការិយាល័យគ្រប់គ្រងគុណភាពទឹក និងដី

-ការិយាល័យគ្រប់គ្រងសំណល់រឹងនិងសារធាតុប្រកបដោយគ្រោះថ្នាក់

-ការិយាល័យគ្រប់គ្រងគុណភាពខ្យល់ សម្លេង និងរំញ័រ នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

-ប្រធាន អនុប្រធាន មន្ទីរបរិស្ថានខេត្ត-ក្រុង និងប្រធាន អនុប្រធានការិយាល័យ ត្រួតពិនិត្យការបំពុលបរិស្ថាននិងអប់រំផ្សព្វផ្សាយព័ត៌មានបរិស្ថាន

ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងបរិស្ថាន ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងបរិស្ថាន និងការដឹកនាំសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធីនិងវិធានស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

**ប្រការ ២** អនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ១ ខាងលើប្រើប្រាស់ជាផ្លូវការ នូវគំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថានរួមមានៈ

-កំណត់ហេតុបណ្តឹង របាយការណ៍

-កំណត់ហេតុស្តាប់កសិណសាក្សី

-កំណត់ហេតុបទល្មើសជាក់ស្តែង

-កំណត់ហេតុប្រមូលនិងឃាត់ទុកវត្ថុតាងនៃបទល្មើសជាក់ស្តែង

-កំណត់ហេតុស្តីពីការយកគំរូតាងមកវិភាគ

-របាយការណ៍វាយតម្លៃពីការខូចខាតបរិស្ថានដែលបណ្តាលមកពីបទល្មើស

-កំណត់ហេតុស្តីពីការចាប់ខ្លួន ឃាត់ខ្លួនពីបទល្មើសជាក់ស្តែង

-កំណត់ហេតុប្រគល់និងទទួលគ្រប់គ្រងវត្ថុតាង

-កំណត់ហេតុប្រគល់និងទទួលជនដែលត្រូវចាប់ខ្លួន ឃាត់ខ្លួនពីបទល្មើសជាក់ស្តែង

-កំណត់ហេតុសួរចម្លើយជនល្មើស

-វិញ្ញាបនប័ត្រកោសល្យវិច័យគំរូតាង

-កំណត់ហេតុចុះពិនិត្យទីកន្លែងកើតហេតុ

-កំណត់ហេតុសាកសួរបំភ្លឺ

-កំណត់ហេតុស្តីពីការឆែកឆេរ

-របាយការណ៍សំយោគ
-កំណត់ហេតុនៃបទល្មើស
-សាលកប័ត្រទោសទណ្ឌ
-ព្រឹត្តិប័ត្រព័ត៌មានជនល្មើស
-សេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍លើជនល្មើស
-ដីកាបញ្ជូនឬដីកាអមទៅព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

ដូចមានភ្ជាប់មកជាមួយនេះ ដើម្បីអោយមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថានងាយស្រួលបំពេញបែបបទប្រតិបត្តិការរបស់ខ្លួនអោយបានសមស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមានបញ្ញត្តិ ។

**ប្រការ ៣** មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ១ ខាងលើតុលាការគ្រប់ខេត្តក្រុងនិងអយ្យការអមតុលាការខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមគំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថានដូចមានចែងក្នុងប្រការ២ ខាងលើតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**ម៉ុក សារ៉េត**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**នាង ស៊ីថុង**

<u>ចម្លងជូន</u>
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្តី
-តុលាការកំពូល មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-គ្រប់ក្រសួង ស្ថាប័ន
-អភិបាលខេត្ត-ក្រុង
-ដើម្បីជូនជ្រាប
-ដូចប្រការ ៣
ដើម្បីអនុវត្ត
ឯកសារ-កាលប្បវត្តិ

លេខ០៣៣ ប្រក.បស្ត.ចល
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ធ្វើនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៣
ត.ប.រដ្ឋមន្ត្រី
អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ

**សែម សារឿន**